ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ៣៤៤ MOC / M 2003

រាជធានីភ្នំពេញ . ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៣

# ប្រកាស

## ស្តីពីការបំពេញបន្ថែម ការដាក់ឱ្យដេញថ្លៃលើកូតាសំលៀកបំពាក់ ដែលត្រូវនាំចេញ ទៅកាន់ប្រទេសកាណាដា សំរាប់ឆ្នាំ២០០៤

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- យោងអនុស្សារណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលកាណាដា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទាក់ទងទៅនឹងការនាំចេញពីប្រទេសកម្ពុជា នូវផលិតផលវាយនភ័ណ្ឌសំរាប់នាំចូលទៅកាន់ប្រទេសកាណាដា ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៩
- យោងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម លេខ ៣២៨ MOC/M2003 ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០៣
- បានឃើញការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ ១ :** បំពេញបន្ថែមប្រការ២ នៃប្រកាសលេខ ៣២៨ MOC/M2003 ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៣ របស់ក្រសួងពាណិជ្ជកម្ម ដូចខាងក្រោមនេះ :

កូតាទាំង៥ប្រភេទខាងលើ ដែលត្រូវដាក់ឱ្យដេញថ្លៃ គឺអនុវត្តចំពោះតែរោងចក្រកាត់ដេរណា ដែលប្រភពនាំចូល វត្ថុធាតុដើម និង ក្រណាត់ មានប្រភពមកពីបណ្តាប្រទេសក្រីក្រ ( ប្រទេស



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

មានការអភិវឌ្ឍន៍តិចតួច) (Least Developed Countries "LDCs") និងប្រទេសដែលស្ថិតនៅក្នុងតារាងអនុគ្រោះពន្ធគយទូទៅ (General Preferential Tariff "GPT" ) ឬក្រៅពីប្រទេសកាណាដា ដូចជាតៃវ៉ាន់ ជាដើម ។

ចំពោះអ្នកនាំចេញសំលៀកបំពាក់ទៅកាន់ប្រទេសកាណាដា ដែលគោរពទៅតាមវិធាននៃប្រភពដើមទំនិញ (Rules of Origin) ដូចបានកំណត់នៅក្នុងសៀវភៅមគ្គុទ្ទេសក៍ស្តីពីគំនិតផ្តួចផ្តើមនៃការឈានចូលទីផ្សារសំរាប់បណ្តាប្រទេសក្រីក្រ និងតារាងពន្ធគយនៃបណ្តាប្រទេសក្រីក្រ ខែធ្នូ ឆ្នាំ២០០២ (An Introductory Guide for the Least Developed Country and the Least Developed Country Tariff, December 2002) ដែលមានសុពលភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៣ មកនោះ និង បានបញ្ជាក់លក្ខណៈវិនិច្ឆ័យប្រភពដើម "E" - ច្បាប់ស្តីពីផលិតផលសំលៀកបំពាក់២ (Origin Criteria "E" – Apparel Rule 2) វិញ សំលៀកបំពាក់ដែលផលិតចេញពីវត្ថុធាតុដើមជាសរសៃអំបោះចាក់ (Yarn) ឬពីក្រណាត់ (Fabric) ហើយដែលសរសៃអំបោះចាក់ និងក្រណាត់នោះ មានប្រភពដើមមកពី បណ្តាប្រទេសក្រីក្រ (LDCs) , ប្រទេសដែលស្ថិតក្នុងតារាងអនុគ្រោះពន្ធគយទូទៅ (GPT) ឬ ពីប្រទេសកាណាដាផ្ទាល់ ព្រមទាំងតំលៃផលិតក្នុងស្រុក (Local Content Requirement) មានតិចជាង ២៥% ត្រូវបានអនុញ្ញាតិអោយនាំចូលទៅកាន់ប្រទេសកាណាដា ដោយមិនតំរូវកូតា និងមិនតំរូវអោយបង់ពន្ធ ឡើយ ។

ប្រការ ២ : នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, គណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញផលិតករសំលៀកបំពាក់ ត្រូវអនុវត្តន៍ប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចម្លងជូន

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-រាជកិច្ច
-ទូរទស្សន៍ជាតិ - វិទ្យុជាតិ និងកាសែតជាតិ " ដើម្បីផ្សព្វផ្សាយ "
-ឯកសារ-កាលប្បវត្តិ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម -ប្រសិទ្ធ